# ឯកឧត្តម កែវ សុខណៃ ជួបគណៈប្រតិភូក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

នៅព្រឹកថ្ងៃទី០៦ ខែ សីហា ឆ្នាំ២០១០ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ឯកឧត្តម **កែវ សុខណៃ** រដ្ឋលេខាបធិការក្រសួងពាណិជ្ជកម្ម បានទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូវៀតណាម ដឹកនាំដោយលោក **ផាម ធិហ៉ាវ** (Pham The Hao) អគ្គនាយកក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មវៀតណាម និងសមាជិកអមដំណើរ ចំនួន៥៨ រូបទៀត មកពីស្ថាប័នរដ្ឋ និងឯកជនរបស់វៀតណាម មានតំណាងក្រុមហ៊ុន អាជីវកម្ម កសិផល ជលផល សំភារៈសំណង់ ។ល។





លោក **ផាម ធិហ៉ាវ** បានជំរាបជូនពីគោលបំណងនៃជំនួបពិភាក្សានៃគណៈប្រតិភូប្រតិភូវៀតណាម គឺដើម្បីសិក្សាស្វែងយល់ និងពិនិត្យលទ្ធភាពធ្វើការវិនិយោគ នៅកម្ពុជា និងការពង្រីកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច-ពាណិជ្ជកម្ម រវាងប្រទេសទាំងពីរឱ្យកាន់តែប្រសើរឡើង ក្នុងគោលបំណងអនុវត្តតាមស្មារតី នៃកិច្ចប្រជុំរវាងរដ្ឋមន្ត្រី នៃប្រទេសទាំងពីរ គឺរវាងឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា និងឯកឧត្តម **VU HUY HOANG** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មវៀតណាម ក្នុងកិច្ចប្រជុំលើកទី៣ ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម តាមព្រំដែន កាលពីដើមខែ ឧសភា ឆ្នាំ២០១០ នៅទីក្រុង តិន អាន នៃប្រទេសវៀតណាម ដោយមានសមាសភាពចូលរួមមកពី មន្ទីរឧស្សាហកម្ម និងពាណិជ្ជកម្ម និងក្រុមហ៊ុនឯកជនរបស់វៀតណាម ដែលចង់សិក្សាស្វែងយល់ ក្នុងការប្រកបរបរជំនួញនៅកម្ពុជា ។

លោក **ផាម ធិហ៉ាវ** បានថ្លែងអំណរគុណដល់ក្រសួងពាណិជ្ជកម្មកម្ពុជា ដែលបានបង្កលក្ខណៈងាយស្រួល ដល់ក្រុមហ៊ុនវៀតណាម ក្នុងការដាក់តាំងបង្ហាញ និងចរាចរផលិតផលរបស់ខ្លួន តាមរយៈការតាំងពិព័រណ៍ពាណិជ្ជកម្ម ប្រចាំឆ្នាំរបស់វៀតណាមនៅកម្ពុជា ។

ឯកឧត្តមរដ្ឋលេខាធិការ **កែវ សុខណៃ** បានជំរាបជូនអំពីលទ្ធផល នៃការអនុវត្តន៍ តាមស្មារតីនៃកិច្ចប្រជុំនៅខេត្តឡុង អាន ប្រទេសវៀតណាម ដែលបានឯកភាពគ្នា ទៅលើផែនការអភិវឌ្ឍន៍ បណ្តាខេត្ត ជាប់ព្រំដែននៃប្រទេសទាំងពីរកម្ពុជា-វៀតណាម ពិសេសគឺការបង្កើតឱ្យចេញជារូបរាងនូវទីផ្សារព្រំដែន ដើម្បីបង្កលក្ខណៈងាយស្រួលដល់អាជីវករនៃប្រទេសទាំងពីរ ក្នុងការចរាចរផលិតផល និងទំនិញ ឱ្យកាន់តែមានភាពរលូនឡើង ។

អង្គប្រជុំបានតាមដានស្តាប់ជាបន្តបន្ទាប់នៃការធ្វើបទបង្ហាញ ពីមន្ត្រីជំនាញមកពីក្រសួងពាណិជ្ជកម្ម-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)និងតំណាងមកពីសភាពាណិជ្ជកម្មកម្ពុជា ស្តីពីគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពង្រីកនូវទំនាក់ទំនងពាណិជ្ជកម្មទ្វេភាគី-គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីពង្រីកនូវទំនាក់ទំនងវិនិយោគទុនទ្វេភាគី និងសក្តានុពល ក្នុងការអភិវឌ្ឍន៍ទំនាក់ទំនងការវិនិយោគទុន និងពាណិជ្ជកម្មទ្វេភាគីផងដែរ ។

តាមការគ្រោងទុក គណៈប្រតិភូវៀតណាម នឹងបន្តដំណើរទៅកាន់ខេត្តបន្ទាយមានជ័យ និងខេត្ត កំពង់ចាម បន្តទៀត ក្នុងគោលបំណង ស្វែងយល់លើវិស័យវិនិយោគ-ពាណិជ្ជកម្មនៅកម្ពុជា ព្រោះផលិតផលរបស់វៀតណាម មួយចំនួនសមស្រប និងកំរិតជីវភាពប្រើប្រាស់របស់ប្រជាជនកម្ពុជា ។